ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មូលនិធិជាតិ ជំនួយសង្គម

NATIONAL SOCIAL ASSISTANCE FUND

# ផែនការយុទ្ធសាស្រ្ត ទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន នៃមូលនិធិជាតិជំនួយសង្គម

ឆ្នាំ២០២៤

# មាតិកា


អារម្ភកថា ....................................................................................ii

បញ្ជីអក្សរកាត់ ....................................................................................iv

I. សេចក្ដីផ្ដើម ....................................................................................1

ក. អំពីមូលនិធិជាតិជំនួយសង្គម ....................................................................................1

ខ. ការវិភាគស្ថានការណ៍ ....................................................................................2

II. ចក្ខុវិស័យ គោលដៅ និង គោលបំណង ....................................................................................4

III. ការកំណត់ក្រុមគោលដៅ ....................................................................................5

IV. ការរៀបចំសារផ្សព្វផ្សាយ ....................................................................................5

V. វិធីសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន ....................................................................................6

VI. ការអភិវឌ្ឍសមត្ថភាពមន្ត្រីទទួលបន្ទុកផ្នែកទំនាក់ទំនង និងផ្សព្វផ្សាយ ....................................................................................8

VII. ការតាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន .....10

VIII. ផែនការសកម្មភាព និងថវិកា ....................................................................................11

IX. សេចក្ដីសន្និដ្ឋាន ....................................................................................12

ឧបសម្ពន្ធ ១៖ ផែនការសកម្មភាព និងថវិកានៃការអនុវត្តផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននៃមូលនិធិជាតិជំនួយសង្គម ....................................................................................13

# អារម្ភកថា

មូលនិធិជាតិជំនួយសង្គម (**ម.ជ.ជ.**) គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្មីមួយ ដែលបានចាប់ផ្តើមដំណើរការជាផ្លូវការនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ដែលមានកាតព្វកិច្ចអនុវត្តកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.** ។ មូលនិធិជាតិជំនួយសង្គម មានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាណាព្យាបាលហិរញ្ញវត្ថុ។ ក្រោមការជួយជ្រោមជ្រែងពីស្ថាប័នអាណាព្យាបាលទាំងពីរ និងដៃគូអភិវឌ្ឍន៍នានា **ម.ជ.ជ.** បាននិងកំពុងទទួលបានការអភិវឌ្ឍស្ថាប័នជាបន្តបន្ទាប់ ព្រមទាំងការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងការអនុវត្តការងារស្នូលរបស់ខ្លួនផងដែរ។

ស្របពេលដែលការអនុវត្តកម្មវិធីជាតិជំនួយសង្គម បាននិងកំពុងដំណើរការជាប្រចាំ និងបម្រើដល់សេចក្តីត្រូវការរបស់គ្រួសារងាយរងគ្រោះ និងក្រុមគោលដៅនានា ការអនុវត្តការងារទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មាន អំពីដំណើរការ លក្ខខណ្ឌ និងអត្ថប្រយោជន៍នៃកម្មវិធីនីមួយៗ ពិតជាមានសារៈសំខាន់ខ្លាំងណាស់។ ផ្អែកតាមការស្រាវជ្រាវមួយចំនួនបានបង្ហាញថា ក្រុមគោលដៅដែលជាគ្រួសារក្រីក្រ និងក្រុមគោលដៅនានាបានទទួលព័ត៌មានផ្សេងៗអំពីកម្មវិធីជំនួយសង្គម តាមរយៈអាជ្ញាធរភូមិ ឃុំ ការប្រជុំតាមសហគមន៍ និងការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងទំនើប។ ទោះបីជាយ៉ាងនេះក្តី ការទទួលបានព័ត៌មានអំពីកម្មវិធីជំនួយសង្គមនានានៅមានកម្រិតក្នុងចំណោមក្រុមគោលដៅដោយសារកត្តាជាច្រើន ក្នុងនោះ ការកម្រិតក្នុងការរៀបចំផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន ក៏ជាកត្តាចម្បងមួយផងដែរ។ ដោយសារកត្តាប្រជាសាស្ត្រ និងភូមិសាស្ត្ររបស់អ្នកទទួលផល និងអ្នកពាក់ព័ន្ធមានភាពខុសប្លែកគ្នាខ្លាំង វាទាមទារឱ្យការរៀបចំផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន ឱ្យបានលម្អិត និងត្រូវអនុវត្តឱ្យបានព្រមៗគ្នា ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃការងារទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន។

កម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ស្ថិតនៅក្នុងសរសរស្តម្ភទាំងពីរនៃប្រព័ន្ធគាំពារសង្គម។ ហេតុនេះ **ម.ជ.ជ.** បានរៀបចំចងក្រងផែនការយុទ្ធសាស្ត្រទំនាក់ទំនងនិងផ្សព្វផ្សាយព័ត៌មាននេះឡើង ដោយអនុលោមទៅតាមយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយគាំពារសង្គម របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលមានអន្តរាគមន៍យុទ្ធសាស្ត្រចំនួន៩ ត្រូវបានកំណត់ដើម្បីសម្រេចបាននូវគោលដៅនៃការទំនាក់ទំនង និងផ្សព្វផ្សាយ រួមមាន៖ **អន្តរាគមន៍ទី១**.ការធ្វើឱ្យប្រសើរឡើងនូវកិច្ចសហការនិងការសម្របសម្រួលអន្តរក្រសួង **អន្តរាគមន៍ទី២**.ការធ្វើឱ្យប្រសើរឡើងនូវភាពជាដៃគូក្នុងការទំនាក់ទំនង និងផ្សព្វផ្សាយ **អន្តរាគមន៍ទី៣**.ការកសាងសមត្ថភាព **អន្តរាគមន៍ទី៤**.ការផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធនិងការចូលរួម **អន្តរាគមន៍ទី៥**.ទំនាក់ទំនងជាមួយសារព័ត៌មាន **អន្តរាគមន៍ទី៦**.ការអភិវឌ្ឍសម្ភារផ្សព្វផ្សាយព័ត៌មាន អប់រំ និងទំនាក់ទំនង(IEC) **អន្តរាគមន៍ទី៧**.ទំនាក់ទំនងនិងផ្សព្វផ្សាយសម្រាប់យន្តការកម្មវិធីជំនួយសង្គមឆ្លើយតបទៅនឹងគ្រោះអាសន្ន **អន្តរាគមន៍ទី៨**.ការបញ្ជ្រាបមាតិកាកម្មវិធីជំនួយសង្គមក្នុងកម្មវិធីសិក្សា និង **អន្តរាគមន៍ទី៩**. ការតាមដាននិងវាយតម្លៃ។

ផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននេះ ក៏បានកំណត់ផងដែរនូវការបណ្តុះបណ្តាលអភិវឌ្ឍន៍សមត្ថភាពសម្រាប់មន្ត្រីទទួលបន្ទុកការងារផ្នែកទំនាក់ទំនងសាធារណៈ និងផ្នែកប្រព័ន្ធផ្សព្វផ្សាយ ដើម្បីធានាថារាល់ការផលិត និងការផ្សព្វផ្សាយព័ត៌មាន អំពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលស្ថិតក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.** មានភាពច្បាស់លាស់ ត្រឹមត្រូវ និងឆ្លើយតបទៅនឹងតម្រូវការព័ត៌មានរបស់ក្រុមគោលដៅ។

ដើម្បីធានាប្រសិទ្ធភាព និងភាពដែលអាចបត់បែនបាន នៃការអនុវត្តផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននេះ **ម.ជ.ជ.** បានសម្រេចដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្តរយៈពេល៣ឆ្នាំ (២០២៤-២០២៦) ដោយត្រូវប្រើប្រាស់ថវិការដ្ឋ និងការកៀរគរធនធានពីគ្រប់មជ្ឈដ្ឋាន ដើម្បីផលិត និងផ្សព្វផ្សាយព័ត៌មាន។ បន្ទាប់ពីរយៈពេល៣ឆ្នាំនេះ **ម.ជ.ជ.** នឹងពិនិត្យមើលឡើងវិញអំពីប្រសិទ្ធភាព និងរិះរកមធ្យោបាយផ្សព្វផ្សាយបន្ថែមទៀត ប្រសិនបើ **ម.ជ.ជ.** រកឃើញនូវចំណុចដែលត្រូវកែលម្អនានា។

ក្នុងនាមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកមូលនិធិជាតិជំនួយសង្គម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងាររបស់ **ម.ជ.ជ.** បណ្តាក្រសួង ស្ថាប័ន ភាគីពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលបានចូលរួមផ្តល់ធាតុចូល និងកិច្ចសហការយ៉ាងល្អ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានរបស់**ម.ជ.ជ.** នេះ។

ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះការជួយជ្រោមជ្រែងយ៉ាងពេញទំហឹងពីសំណាក់ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់សម្រាប់ការអភិវឌ្ឍអន្តរជាតិ(GIZ) ដែលនាំឱ្យការកសាងផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន របស់**ម.ជ.ជ.** នេះ មានភាពគ្រប់ជ្រុងជ្រោយ។

ជាមួយគ្នានេះដែរ ខ្ញុំក៏សូមអំពាវនាវនិងលើកទឹកចិត្តដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ សូមបន្តផ្តល់ការគាំទ្រនិងកិច្ចសហការល្អ ក្នុងការអនុវត្តនូវផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននេះ ដើម្បីជាឧត្តមប្រយោជន៍ដល់ប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជាយើង។

ថ្ងៃចន្ទ ១១កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ពុទ្ធស័ករាជ ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ២០២៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជាអគ្គនាយក**

**ស៊ឹម សុធន**

## បញ្ជីអក្សរកាត់

| | |
|---|---|
| CD-SPiC | យុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយប្រព័ន្ធគាំពារសង្គមនៅកម្ពុជា |
| GIZ | ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់សម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| GS-NSPC | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម |
| IEC | សម្ភារផ្សព្វផ្សាយព័ត៌មាន អប់រំ និងទំនាក់ទំនង |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoInfo | ក្រសួងព័ត៌មាន |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| NSAF | មូលនិធិជាតិជំនួយសង្គម |
| NSPC | ក្រុមប្រឹក្សាជាតិគាំពារសង្គម |
| NSPPF | ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម |
| SA | ជំនួយសង្គម |
| SP | គាំពារសង្គម |
| SPiC | គាំពារសង្គមនៅកម្ពុជា |
| SS | សន្តិសុខសង្គម |

# I. សេចក្តីផ្តើម

## ក. អំពីមូលនិធិជាតិជំនួយសង្គម (ម.ជ.ជ.)

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តលើក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម (NSPPF) ២០១៦-២០២៥ នៅឆ្នាំ២០១៦។ នៅក្រោមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមនេះ ប្រព័ន្ធគាំពារសង្គមនៅកម្ពុជាបានបែងចែកជាសសរស្តម្ភចំនួន២ រួមមាន៖ ប្រព័ន្ធសន្តិសុខសង្គម និងប្រព័ន្ធជំនួយសង្គម។ នៅដើមឆ្នាំ២០២២ មូលនិធិជាតិជំនួយសង្គម **(ម.ជ.ជ.)** ត្រូវបានបង្កើតឡើងជាគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្មីមួយ ស្របតាមអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ដោយសមាហរណកម្មរវាងបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល **(ប.ជ.ស.)** បេឡាជាតិអតីតយុទ្ធជន **(ប.ជ.អ.)** និងផ្នែកខ្លះនៃមូលនិធិជនពិការ **(ម.ជ.ព.)**។ មូលនិធិជាតិជំនួយសង្គម មានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអាណាព្យាបាលហិរញ្ញវត្ថុ។

មូលនិធិជាតិជំនួយសង្គម**(ម.ជ.ជ.)** ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ដោយមានកាតព្វកិច្ចអនុវត្តកម្មវិធីនិងរបបសំខាន់ៗចំនួនពីរ ។ ទី១គឺ កម្មវិធីជំនួយសង្គម ក្នុងនោះរួមមាន៖ (១).កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ (២).កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ (៣).កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់ សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋមានការលំបាកផ្នែកជីវភាព ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកស្លាប់ ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ (៤).កម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់គម្រោងកិច្ចគាំពារសង្គមដើម្បីបញ្ចប់ភាពក្រីក្រ (៥).កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា (៦).កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ និងគ្រោះមហន្តរាយផ្សេងៗ (៧).កម្មវិធីជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និង (៨).ការបណ្តុះបណ្តាលនិងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ។ល។ ទី២គឺ របបសន្តិសុខសង្គម ដែលរួមមាន៖ ការបើកផ្តល់ប្រាក់គោលនយោបាយរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងអ្នកនៅក្នុងបន្ទុក។

នៅក្នុងដំណាក់កាលនេះ **ម.ជ.ជ.** កំពុងពង្រឹងសមត្ថភាពរបស់ខ្លួន និងស្វែងរកការគាំទ្រទាំងផ្នែកបច្ចេកទេស ទាំងផ្នែកហិរញ្ញវត្ថុ ដើម្បីធ្វើឱ្យស្ថាប័នមួយនេះមានភាពល្អប្រសើរ ក្លាយជាស្វ័យប្រតិបត្តិករលើកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមមួយចំនួន ដែលស្ថិតក្រោមអាណត្តិកិច្ចការងាររបស់ **ម.ជ.ជ.** ។ **ម.ជ.ជ.** បាននិងកំពុងផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងពីកម្មវិធីជំនួយសង្គមទៅគ្រប់ភាគីពាក់ព័ន្ធ ដើម្បីសម្រេចគោលដៅរួមនៃការពង្រឹងសមត្ថភាពស្ថាប័ន។ ដើម្បីឱ្យការបញ្ជ្រាបព័ត៌មាន មានភាពទូទៅនិងទូលំទូលាយអំពីការអនុវត្តកម្មវិធី និងរបបនានា **ម.ជ.ជ.**ត្រូវការយ៉ាងចាំបាច់នូវផែនការយុទ្ធសាស្ត្រ ទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានមួយដែលសមស្រប និងអាចអនុវត្តបាន សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំផែនការ

ទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន ក្នុងក្របខណ្ឌផ្ទៃក្នុង និងក្របខណ្ឌខាងក្រៅស្ថាប័ន ការរៀបចំផលិតសម្ភារផ្សព្វផ្សាយព័ត៌មាន អប់រំ និងទំនាក់ទំនង ព្រមទាំងការរៀបចំផែនការផ្សព្វផ្សាយផ្ទាល់តាមសហគមន៍តាមគ្រប់មធ្យោបាយ ដោយសហការ ជាមួយដៃគូអភិវឌ្ឍន៍ អង្គការបណ្តាញ និងអង្គការមិនមែនរដ្ឋាភិបាលនានា សំដៅបញ្ជូនព័ត៌មានអំពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.** ឱ្យទៅដល់ក្រុមគោលដៅ គ្រប់ទីកន្លែង។

នាពេលកន្លងមក **ម.ជ.ជ.** ក៏បានផ្សព្វផ្សាយនូវសកម្មភាពរបស់ខ្លួនតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានារួមមានវិទ្យុ ទូរទស្សន៍ បណ្តាញសង្គម សិក្ខាសាលា កិច្ចប្រជុំ និង ការផ្សព្វផ្សាយដោយផ្ទាល់ដល់ក្រុមគោលដៅនានា នៅតាមសហគមន៍ ។ ទោះបីជាយ៉ាងនេះក្តី ការអនុវត្តការងារទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានត្រូវពង្រឹងនិងពង្រីកបន្ថែមទៀត ដោយប្រើប្រាស់នូវអន្តរាគមន៍ឬវិធីសាស្ត្រសំខាន់ៗសមស្រប ដែលអាចបញ្ជូនព័ត៌មានទៅដល់ក្រុមគោលដៅបានច្រើនព្រមៗគ្នាក្នុងពេលតែមួយនិងរហ័ស។

## ខ. ការវិភាគស្ថានការណ៍

នៅក្នុងកិច្ចដំណើរការរៀបចំផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននេះ **ម.ជ.ជ.** បានរៀបចំកិច្ចពិភាក្សាជាមួយមន្ត្រីជំនាញពាក់ព័ន្ធមកពីគ្រប់នាយកដ្ឋាននៃ **ម.ជ.ជ.** និងបានពិនិត្យឯកសារលទ្ធផលនៃការសិក្សាស្រាវជ្រាវដែលមានស្រាប់ ដើម្បីឱ្យការរៀបចំផែនការយុទ្ធសាស្ត្រនេះគ្រប់ជ្រុងជ្រោយ និងអាចផ្តល់គុណតម្លៃបន្ថែមដល់ការងារទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន អំពីកម្មវិធីជំនួយសង្គមនិងរបបសន្តិសុខសង្គម ដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.** ដល់ក្រុមគោលដៅឱ្យបានកាន់តែទូលំទូលាយនិងមានប្រសិទ្ធភាព។

ការរៀបចំផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននេះ បានអនុលោមទៅតាមយុទ្ធសាស្ត្រទំនាក់ទំនងនិងផ្សព្វផ្សាយគាំពារសង្គមកម្ពុជា។ មូលនិធិជាតិជំនួយសង្គម បានអនុវត្តតាមអន្តរាគមន៍ទាំង៩នៃយុទ្ធសាស្ត្រទំនាក់ទំនងនិងផ្សព្វផ្សាយគាំពារសង្គមកម្ពុជា និងបានរៀបចំជាផែនការសកម្មភាពសម្រាប់អនុវត្តការងារទំនាក់ទំនងនិងផ្សព្វផ្សាយព័ត៌មាន ក្នុងក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមសម្រាប់៣ឆ្នាំដំបូង (២០២៤-២០២៦)។

លើសពីនេះ ផ្អែកលើការសិក្សាស្រាវជ្រាវអំពីការយល់ដឹងនិងការទទួលបានព័ត៌មានអំពីប្រព័ន្ធគាំពារសង្គមកម្ពុជា នាខែសីហា ឆ្នាំ២០២១ បានបង្ហាញថា ក្នុងចំណោមអ្នកឆ្លើយតបចំនួន១.០០៣រូប ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ មានអ្នកចូលរួមចំនួន៨៥% បានយល់ដឹងអំពីការផ្តល់សាច់ប្រាក់សម្រាប់គ្រួសារក្រីក្រនិងងាយរងគ្រោះដែលបណ្តាលមកពីជំងឺកូវីដ-១៩ អ្នកចូលរួមចំនួន៥៤% បានយល់ដឹងអំពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ និងអ្នកចូលរួមចំនួន៤១% បានយល់ដឹងអំពីមូលនិធិសមធម៌សុខាភិបាល[1]។ របាយការណ៍ដដែលនេះក៏បានបង្ហាញដែរថា៥៥% នៃអ្នកដែលបានឆ្លើយតប បានដឹងព័ត៌មានអំពីកម្មវិធីគាំពារសង្គម តាមរយៈអាជ្ញាធរមូលដ្ឋាន ក្នុងនោះ៨៥% ដឹងតាម

[1] Research Study for Cambodia's Citizen's Awareness and Access to Information on Social Protection Schemes, Sep 2021 (n=1,003), p. 6.

រយៈមេភូមិ ខណៈដែលអ្នកឆ្លើយតបចំនួន៤២% ផ្សេងទៀតបានដឹងព័ត៌មានអំពីកម្មវិធីគាំពារសង្គមតាមរយៈមិត្តភក្តិឬអ្នកជិតខាង[2]។ របាយការណ៍នេះ ក៏បានបង្ហាញផងដែរ អំពីប្រភពព័ត៌មានដែលអ្នកឆ្លើយតបចង់បាន គឺតាមរយៈអាជ្ញាធរភូមិចំនួន៧១% ប្រព័ន្ធផ្សព្វផ្សាយចំនួន៤៤% អាជ្ញាធរឃុំ-សង្កាត់ចំនួន៤០% ការផ្សព្វផ្សាយតាមទូរទស្សន៍ចំនួន៣១% និងការផ្សព្វផ្សាយចល័តតាមឧគ្ឃោសនាសព្ទចំនួន២៥%[3] ។ របាយការណ៍នេះក៏បានបន្ថែមទៀតថា អ្នកឆ្លើយតបចំនួន៧៤% មានការលំបាកក្នុងការទទួលព័ត៌មានអំពីប្រព័ន្ធគាំពារសង្គម ដោយសារពួកគាត់មិនដឹងថាត្រូវទៅរកព័ត៌មានទាំងនោះអំពីអ្នកណា និងចំនួន៣២%[4] បានបង្ហាញថា ព័ត៌មានដែលពួកគាត់បានឃើញមួយចំនួនធ្វើឱ្យពួកគាត់យល់ច្រឡំ។

ការស្រាវជ្រាវមួយចំនួនទៀតបានបង្ហាញថា ប្រជាជនកម្ពុជាបានទទួលព័ត៌មានអំពីប្រព័ន្ធផ្សព្វផ្សាយច្រើនជាងពីគ្រួសារនិងមិត្តភក្តិនៅក្នុងសហគមន៍របស់ខ្លួន។ ក្នុងនោះ ទូរសព្ទដៃជាឧបករណ៍ដែលត្រូវបានប្រើប្រាស់សម្រាប់ទទួលព័ត៌មានច្រើនជាងគេ បន្ទាប់មកគឺតាមរយៈអ៊ិនធឺណិត និងទូរទស្សន៍ [5]។

ការស្រាវជ្រាវដែលបានបង្ហាញទៀតថា៖

- ៨៧% នៃប្រជាជនកម្ពុជាមានទូរសព្ទដៃប្រើប្រាស់
- ១២,៥លាននាក់(ក្នុងចំណោមប្រជាជនចំនួន១៦,៤លាននាក់) នៃប្រជាជនកម្ពុជាជាអ្នកសកម្មក្នុងការប្រើប្រាស់អ៊ិនធើណិត
- ៨,៤លាននាក់ ជាអ្នកសកម្មប្រើប្រាស់បណ្តាញផ្សព្វផ្សាយព័ត៌មានសង្គមនានា
- ៨,៣លាននាក់ ជាអ្នកសកម្មប្រើប្រាស់បណ្តាញផ្សព្វផ្សាយព័ត៌មានសង្គមហ្វេសប៊ុក
- ២០០.០០០ គណនី Twitter ។

អ្នកប្រើប្រាស់បណ្តាញផ្សព្វផ្សាយព័ត៌មានសង្គម មានការកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងប្រទេសកម្ពុជា។ នៅក្នុងឆ្នាំ២០១២ មានប្រជាជនកម្ពុជាត្រឹមតែចំនួន៦៩០.៥២០នាក់ប៉ុណ្ណោះ ប្រើប្រាស់បណ្តាញផ្សព្វផ្សាយព័ត៌មានសង្គម ហើយចំនួនអ្នកប្រើប្រាស់បណ្តាញនេះបានកើនឡើងយ៉ាងខ្លាំងដល់ចំនួន៨,៤លាននាក់ នៅក្នុងឆ្នាំ២០១៩។ ក្នុងនោះ អ្នកប្រើប្រាស់អ៊ិនធឺណិតប្រើប្រាស់បណ្តាញផ្សព្វផ្សាយព័ត៌មានសង្គមហ្វេសប៊ុក (Facebook) ច្រើនជាងគេនៅកម្ពុជា។

វីដេអូ គឺជាឧបករណ៍ទំនាក់ទំនងដ៏សំខាន់ដែលស្ថាប័ននានាបានប្រើប្រាស់ ដើម្បីផ្តល់ព័ត៌មានដល់ក្រុមគោលដៅជាក់លាក់ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញផ្សព្វផ្សាយព័ត៌មានសង្គម។

ការស្រាវជ្រាវបានបង្ហាញថា យុទ្ធនាការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយជាក់លាក់ គឺជាមធ្យោបាយទំនាក់ទំនងដ៏មានប្រសិទ្ធភាព អមដោយការអនុវត្តសកម្មភាពអប់រំតាមសហគមន៍ ហើយបន្ទាប់មកគឺការ

---

[2] Research Study for Cambodia's Citizen's Awareness and Access to Information on Social Protection Schemes, Sep 2021 (n=1,003), p. 6.
[3] Research Study for Cambodia's Citizen's Awareness and Access to Information on Social Protection Schemes, Sep 2021 (n=1,003), p. 6.
[4] Research Study for Cambodia's Citizen's Awareness and Access to Information on Social Protection Schemes, Sep 2021 (n=1,003), p. 6.
(5) Media Mapping: Reflections on Media Consumption Trends, News, Influence and Opportunities for Media Development in Cambodia, August 2019

រៀបចំព្រឹត្តិការណ៍ពិសេសផ្សេងៗ ដែលក្នុងនោះវីដេអូគឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយ។ យុទ្ធនាការនិងវីដេអូទាំងនេះ ត្រូវបានផ្សព្វផ្សាយតាមរយៈបណ្តាញផ្សព្វផ្សាយព័ត៌មានសង្គមហ្វេសប៊ុក ដែលអាចបញ្ជូនព័ត៌មានទៅក្រុមគោលដៅបានច្រើន និងតាមពីក្រោយដោយបណ្តាញផ្សព្វផ្សាយព័ត៌មានសង្គមយូធូប (YouTube) និង អ៊ីនស្តាក្រាម (Instagram)។

ចំពោះការផ្សព្វផ្សាយព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយប្រពៃណី របាយការណ៍បានរកឃើញថា កម្មវិធីព័ត៌មានផ្សព្វផ្សាយតាមរយៈទូរទស្សន៍ និងវិទ្យុ នៅតែទាក់ទាញក្រុមគោលដៅបានច្រើន។ ក្នុងនោះ កម្មវិធីព័ត៌មានរបស់ស្ថានីយ៍ទូរទស្សន៍ហង្សមាស មានចំនួនអ្នកទស្សនាច្រើនជាងគេ បន្ទាប់មកគឺ ទូរទស្សន៍ PNN និងទូរទស្សន៍ CTN។ អ្នកស្តាប់កម្មវិធីព័ត៌មានរបស់វិទ្យុបាយ័ន (Bayon) មានចំនួនច្រើនជាងគេ បន្ទាប់មកគឺវិទ្យុបារាំងអន្តរជាតិ(RFI) វិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា(WMC) និងវិទ្យុវ៉ាយោ (Vayo)។

ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយប្រពៃណីមានការប្រែប្រួលដូចខាងក្រោម៖

- អ្នកទស្សនាទូរទស្សន៍បានធ្លាក់ចុះពីចំនួន៩៥% នៅឆ្នាំ២០១៥, មកត្រឹម៨៦% នៅឆ្នាំ២០១៧ មកត្រឹមចំនួន៧៨% នៅឆ្នាំ២០១៨, និងមកនៅត្រឹមចំនួន៧២% នៅឆ្នាំ២០១៩ [6]
- ការស្តាប់វិទ្យុបានធ្លាក់ចុះមកនៅត្រឹមចំនួន១២% នៅឆ្នាំ២០១៩[7] ប្រៀបធៀបទៅនឹងចំនួន៣៦% នៃការស្តាប់វិទ្យុ២លើកក្នុងមួយសប្តាហ៍ នៅឆ្នាំ២០១៧ និងចំនួន៤៨% នៅឆ្នាំ២០១៥។

## II. ចក្ខុវិស័យ គោលដៅ និងគោលបំណង

### ក. ចក្ខុវិស័យ

ប្រជាពលរដ្ឋគ្រប់រូបដែលជាក្រុមគោលដៅ និងភាគីពាក់ព័ន្ធនានាយល់ដឹង ចូលរួម និងទទួលផលប្រយោជន៍ពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ប្រកបដោយសមធម៌និងបរិយាបន្ន។

### ខ. គោលដៅ

ពង្រឹងនិងពង្រីកការអនុវត្តការងារទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន អំពីកម្មវិធីជំនួយសង្គមនិងរបបសន្តិសុខសង្គម ដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់មូលនិធិជាតិជំនួយសង្គម តាមរយៈកិច្ចសហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និង ប្រព័ន្ធផ្សព្វផ្សាយនានា ព្រមទាំងក្រុមគោលដៅនិងប្រជាពលរដ្ឋទូទៅ។

### គ. គោលបំណង

ផែនការយុទ្ធសាស្ត្រទំនាក់ទំនងនេះត្រូវបានរៀបចំឡើងក្នុងគោលបំណង៖

---
(6) CMRD Cambodia, Media Consumption, August 2019
(7) CMRD Cambodia, Media Consumption, August 2019 (n=2535)

១. ផលិតនិងផ្សព្វផ្សាយ សម្ភារផ្សព្វផ្សាយព័ត៌មាន អប់រំ និងទំនាក់ទំនង និងរៀបចំការងារទំនាក់ទំនងអំពីដំណើរការអនុវត្ត ក្រុមគោលដៅ ផលប្រយោជន៍ និងលទ្ធផលនៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.** ។

២. ធានាថាសារផ្សព្វផ្សាយអំពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់**ម.ជ.ជ.** ច្បាស់លាស់ និងត្រឹមត្រូវ។

៣. ធានាបាននូវភាពស៊ីសង្វាក់គ្នា និងលំហូរព័ត៌មានដែលត្រឹមត្រូវ ទូលំទូលាយ រវាងអាជ្ញាធរពាក់ព័ន្ធ និងអ្នកទទួលផល តាមរយៈការប្រើប្រាស់បណ្តាញ និងថ្នាលផ្សព្វផ្សាយព័ត៌មាននិងទំនាក់ទំនងចម្រុះ។

៤. ពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីអនុវត្តការងារ ផ្នែកទំនាក់ទំនងនិងផ្សព្វផ្សាយព័ត៌មាន និងភាគីពាក់ព័ន្ធផ្សេងទៀតដែលជួយផ្សព្វផ្សាយបន្តអំពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.**។

៥. ជំរុញការតាមដាន និងវាយតម្លៃអំពីការយល់ដឹងរបស់ក្រុមគោលដៅ និងអ្នកពាក់ព័ន្ធនានាអំពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.**។

## III. ការកំណត់ក្រុមគោលដៅ

ក្រុមគោលដៅដែលនឹងជាអ្នកទទួលព័ត៌មានអំពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលស្ថិតក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.**តាមរយៈផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននេះរួមមាន៖

ក្រុមគោលដៅទី១៖ ប្រជាពលរដ្ឋដែលជាក្រុមគោលដៅ នៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗ

ក្រុមគោលដៅទី២៖ អ្នកផ្តល់សេវាជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗ

ក្រុមគោលដៅទី៣៖ ភាគីពាក់ព័ន្ធនានា(ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ម្ចាស់ជំនួយ អង្គការជាតិនិងអន្តរជាតិ អង្គការសហគមន៍មូលដ្ឋាន សង្គមស៊ីវិល វិស័យឯកជន សប្បុរសជន...)

## IV. ការរៀបចំសារអប់រំផ្សព្វផ្សាយ (KEY MESSAGES)

សារអប់រំផ្សព្វផ្សាយគន្លឹះៗ គឺជាមធ្យោបាយដ៏សំខាន់ក្នុងការផ្តល់ព័ត៌មានជាក់លាក់ ច្បាស់លាស់ និងត្រឹមត្រូវទៅដល់ក្រុមគោលដៅជាក់លាក់ណាមួយ។

សារអប់រំផ្សព្វផ្សាយគន្លឹះៗទាក់ទងនឹងកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗនឹងត្រូវផលិត និងផ្សព្វផ្សាយជាភាសាខ្មែរ និងភាសាជនជាតិដើមភាគតិចសម្រាប់ជនជាតិដើមភាគតិច ព្រមទាំងមានការប្រើប្រាស់ភាសាសញ្ញា និងអក្សរស្ទាបសម្រាប់ជនមានពិការភាពថ្លង់ និងពិការភ្នែក។

សារអប់រំផ្សព្វផ្សាយគួរផ្តោតទៅលើ៖

- គោលបំណង វិសាលភាព និងក្រុមគោលដៅនៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម
- ឯកសារគតិយុត្តនានាទាក់ទងនឹងកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម

- របៀប ឬដំណើរការនៃការចូលរួម ឬទទួលផលពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម
- លក្ខខណ្ឌដើម្បីទទួលបានអត្ថប្រយោជន៍ពី កម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម
- ផលប្រយោជន៍នៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗ
- ទីកន្លែង និងពេលវេលានៃការផ្តល់សេវាសាធារណៈនៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម
- ភាគីពាក់ព័ន្ធនានាដែលអាចជួយដល់ក្រុមគោលដៅឱ្យទទួលបានផលប្រយោជន៍អំពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម
- តួនាទី និងភារកិច្ចរបស់អ្នកអនុវត្តនីតិវិធីនៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម
- របៀបផ្តល់ និងការដោះស្រាយមតិជំទាស់ និងសំណូមពរទាក់ទងនឹងការអនុវត្តកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម។ល។
- កាលបរិច្ឆេទនៃការបើកផ្តល់ប្រាក់ឧបត្ថម្ភនៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម។

## V. វិធីសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន

### អន្តរាគមន៍ទី ១ ៖ ការធ្វើឱ្យប្រសើរឡើងនូវកិច្ចសហការ និងការសម្របសម្រួលអន្តរក្រសួង

ក្រុមការងារផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មានរបស់ **ម.ជ.ជ.** មានតួនាទីជាអ្នកសម្របសម្រួល និងដឹកនាំក្រុមការងារផ្នែកទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានរបស់ក្រសួង ស្ថាប័នដែលទទួលបន្ទុកអនុវត្តការងារកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.** ក្នុងការរៀបចំផែនការសកម្មភាព និងដោះស្រាយបញ្ហាប្រឈមផ្សេងៗ។

### អន្តរាគមន៍ទី ២ ៖ ការធ្វើឱ្យប្រសើរឡើងនូវភាពជាដៃគូក្នុងការទំនាក់ទំនង និងផ្សព្វផ្សាយ

ក្រុមការងារផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន របស់ **ម.ជ.ជ.** ត្រូវបង្កើតកិច្ចសហការជាមួយក្រសួង ស្ថាប័នជាតិ អង្គការជាតិនិងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ សហគមន៍មូលដ្ឋាន និងវិស័យឯកជន ដើម្បីបង្កើតព្រឹត្តិការណ៍អប់រំ ផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងអំពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.** ដល់ក្រុមគោលដៅឱ្យបានទូលំទូលាយ និងគ្រប់មធ្យោបាយសមស្រប។

### អន្តរាគមន៍ទី ៣ ៖ ការកសាងសមត្ថភាព

មូលនិធិជាតិជំនួយសង្គម ផ្តល់ការកសាងសមត្ថភាពដល់មន្ត្រី ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធជាប្រចាំ ដើម្បីកសាងមូលដ្ឋាន និងបង្ហាញអំពីសារៈសំខាន់ក្នុងការអភិវឌ្ឍកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់ខ្លួន ជាពិសេសការអនុវត្តផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយ។

### អន្តរាគមន៍ទី ៤ ៖ ការផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ និងការចូលរួម

ក្រុមការងារផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មានរបស់ **ម.ជ.ជ.** រៀបចំការផ្សព្វផ្សាយពង្រឹងការយល់ដឹង និងធ្វើបច្ចុប្បន្នភាពអំពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់**ម.ជ.ជ.** ដោយផ្ទាល់ដល់ស្ថាប័នជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល

អង្គការសហគមន៍មូលដ្ឋាន និង អ្នកពាក់ព័ន្ធនានា តាមរយៈសិក្ខាសាលា កិច្ចប្រជុំ បទបង្ហាញ ឬ ព្រឹត្តិការណ៍នានា និងដោយប្រយោលតាមរយៈប្រព័ន្ធវីដេអូ Zoom ឬ webinar ទៅតាមពេលវេលាជាក់លាក់ និងជាបន្តបន្ទាប់។

ការរៀបចំផ្សព្វផ្សាយផ្ទាល់តាមសហគមន៍តូចៗ ដោយប្រើប្រាស់ឧបករណ៍ផ្សព្វផ្សាយគ្រប់ប្រភេទ និងមានជាភាសាជនជាតិដើមភាគតិច ព្រមទាំងភាសាសញ្ញាសម្រាប់ជនមានពិការភាព។

**អន្តរាគមន៍ទី ៥ ៖ ទំនាក់ទំនងជាមួយសារព័ត៌មាន**

ក្រុមការងារផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន របស់ **ម.ជ.ជ.** ត្រូវពង្រឹងនិងពង្រីកកិច្ចសហការរវាងក្រុមការងារ និងប្រព័ន្ធផ្សព្វផ្សាយនានា ដើម្បីសម្រួលដល់ការចុះប្រមូលព័ត៌មាន និងរាយការណ៍ព័ត៌មាន អំពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់**ម.ជ.ជ.** ។ ក្រុមការងារផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន របស់ **ម.ជ.ជ.** ត្រូវបង្កើតសកម្មភាពឬព្រឹត្តិការណ៍នានា ដើម្បីឱ្យប្រព័ន្ធផ្សព្វផ្សាយអាចស្វែងយល់ឱ្យបានលម្អិត អាចជួបអ្នកទទួលផលដោយផ្ទាល់នៅតាមមូលដ្ឋាន និងអាចផ្សព្វផ្សាយព័ត៌មានពីសហគមន៍មកអ្នកអនុវត្តគោលនយោបាយវិញ ដើម្បីបង្កើនប្រសិទ្ធភាពនៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.** ។ក្រុមការងារអាចសហការជាមួយប្រព័ន្ធផ្សព្វផ្សាយរៀបចំផលិតកម្មវិធីវិទ្យុ ទូរទស្សន៍ ឬ ឌីជីថលនានាតាមដែលអាចធ្វើទៅបាន ដើម្បីបង្កើនការចូលរួមពីប្រព័ន្ធផ្សព្វផ្សាយ និងពង្រីកវិសាលភាពនៃការផ្សាយដល់សាធារណៈជនទូទៅ។

**អន្តរាគមន៍ទី ៦ ៖ ការអភិវឌ្ឍសម្ភារផ្សព្វផ្សាយព័ត៌មាន អប់រំ និងទំនាក់ទំនង (IEC)**

ក្រុមការងារផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន របស់ **ម.ជ.ជ.** សហការជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា ដើម្បីផលិតសម្ភារផ្សព្វផ្សាយព័ត៌មាន អប់រំ និងទំនាក់ទំនង (IEC) ដែលមានដូចជា ឯកសារបោះពុម្ពផ្សាយឯកសារជាវីដេអូ ឯកសារជាសំឡេង ឯកសារជាប្រភេទឌីជីថលនានា ទាក់ទងនឹងកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់**ម.ជ.ជ.** ដើម្បីឱ្យក្រុមគោលដៅ សាធារណៈជន និង អ្នកពាក់ព័ន្ធនានាបានយល់ដឹងអំពីដំណើរការ និងការទទួលបានផលប្រយោជន៍ពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗ។ លើសពីនេះ ក្រុមការងារផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន របស់ **ម.ជ.ជ.** ត្រូវបញ្ជូននូវកញ្ចប់សម្ភារផ្សព្វផ្សាយព័ត៌មាន អប់រំ និងទំនាក់ទំនង ដែលបានផលិតរួចទៅដល់ប្រព័ន្ធផ្សព្វផ្សាយនានា ដោយសមធម៌ និងបរិយាបន្ន ដើម្បីឱ្យប្រព័ន្ធផ្សព្វផ្សាយជួយផ្សព្វផ្សាយបន្ត។ ទន្ទឹមនឹងនេះក្រុមការងារផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន របស់ **ម.ជ.ជ.** ត្រូវសហការរៀបចំបង្កើតឱ្យមាននិមិត្តសញ្ញាជាអត្តសញ្ញាណសម្គាល់ស្ថាប័ន និងជាមធ្យោបាយក្នុងការផ្សព្វផ្សាយអំពីស្ថាប័នដល់សាធារណៈជនដូចជាការបង្កើតនិមិត្តសញ្ញា សម្រាប់បំពាក់ជាប់អាវ គំរូស្លាយបទបង្ហាញ ការដាក់និមិត្តសញ្ញា (ឡូហ្គោ) លើរូបថតនិងវីដេអូ ព្រមទាំង បង្កើតរបៀបប្រើប្រាស់និមិត្តសញ្ញា(Branding) ឱ្យបានសមស្រប ដើម្បីធានាភាពត្រឹមត្រូវ និងច្បាស់លាស់។

**អន្តរាគមន៍ទី ៧ ៖ ទំនាក់ទំនង និងផ្សព្វផ្សាយសម្រាប់យន្តការកម្មវិធីជំនួយសង្គមឆ្លើយតបទៅនឹងគ្រោះអាសន្ន**

ក្រុមការងារផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន របស់ **ម.ជ.ជ.** ត្រូវសហការយ៉ាងមោះមុតជាមួយក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីប្រើប្រាស់យន្តការផ្សព្វផ្សាយជាតិគាំពារសង្គម ដែលមានស្រាប់ ក្នុងការផ្សព្វផ្សាយនូវរាល់ព័ត៌មានបន្ទាន់ អំពីការអនុវត្តលក្ខខណ្ឌ និងដំណើរការប្រព្រឹត្តិទៅនៃកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដើម្បីឱ្យសាធារណៈជនបានទទួលព័ត៌មានឆាប់រហ័ស មានការចូលរួម និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្ត។ ក្នុងករណីចាំបាច់ ក្រុមការងារផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន របស់ **ម.ជ.ជ.** ត្រូវរិះរកមធ្យោបាយក្នុងការពង្រីកវិសាលភាពនៃការផ្សព្វផ្សាយនេះ ដោយពិនិត្យមើលលើកិច្ចអន្តរាគមន៍ទី៤ និងទី៥។

**អន្តរាគមន៍ទី ៨ ៖ ការបញ្ជ្រាបមាតិកាកម្មវិធីជំនួយសង្គមក្នុងកម្មវិធីសិក្សា**

ក្រុមការងារផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន របស់ **ម.ជ.ជ.** សហការជាមួយក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីសិក្សានិងពិនិត្យលទ្ធភាពជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបញ្ចូលមេរៀនអំពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលស្ថិតក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.** ទៅក្នុងកម្មវិធីសិក្សារបស់សិស្សានុសិស្សនៅកម្រិតទុតិយភូមិ និងគួរផ្តោតលើមុខវិជ្ជាពលរដ្ឋវិជ្ជា ដើម្បីឱ្យសិស្សានុសិស្សបានយល់ដឹងអំពីតួនាទី និងផលប្រយោជន៍នៃកម្មវិធីជំនួយសង្គម សម្រាប់លើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ។ លើសពីនេះ ក្រុមការងារផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន របស់ **ម.ជ.ជ.** សហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន ឬអ្នកពាក់ព័ន្ធនានា រៀបចំផលិតសម្ភារព័ត៌មានចម្រុះដែលអាចឱ្យសិស្សានុសិស្សសិក្សារៀនសូត្រ នៅតាមបណ្ណាល័យ ឬទាញយកមកសិក្សាតាមរយៈប្រព័ន្ធអនឡាញ។ ក្រុមការងារក៏អាចចុះអប់រំ និងផ្សព្វផ្សាយដោយផ្ទាល់ នៅតាមសាលារៀនបន្ទាប់ពីកម្មវិធីគោរពទង់ជាតិ ឬកម្មវិធីបំណិនជីវិតនានា រួមនឹងការបិទផ្សាយសម្ភារៈបោះពុម្ពចែកផ្សាយ តាមសាលារៀន ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលនានាផងដែរ។

**អន្តរាគមន៍ទី ៩ ៖ ការតាមដាន និងវាយតម្លៃ**

មូលនិធិជាតិជំនួយសង្គម ត្រូវបង្កើតក្រុមការងារតាមដាននិងវាយតម្លៃ ដើម្បីតាមដាននិងវាយតម្លៃលើការអនុវត្តការងារទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន ដើម្បីស្វែងយល់អំពីប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ ព្រមទាំងកែសម្រួលការអនុវត្តការងារទំនាក់ទំនង និងផ្សព្វផ្សាយ ឱ្យកាន់តែមានប្រសិទ្ធភាពស្របតាមការរីកចម្រើននៃបច្ចេកវិទ្យា និងមធ្យោបាយក្នុងការទទួលព័ត៌មានរបស់ក្រុមគោលដៅ។

## VI. ការអភិវឌ្ឍសមត្ថភាពមន្ត្រីទទួលបន្ទុកផ្នែកទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន

ការបណ្តុះបណ្តាលសមត្ថភាពជាប្រចាំដល់មន្ត្រីផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន របស់ **ម.ជ.ជ.** ពិតជាមានសារៈសំខាន់ណាស់ដើម្បីបង្កើតប្រសិទ្ធភាពក្នុងការរៀបចំផែនការ ការគ្រប់គ្រង ការអនុវត្ត និងការវាយតម្លៃការងារទំនាក់ទំនងនិងផ្សព្វផ្សាយ។ **ម.ជ.ជ.** ត្រូវសហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការជាតិ អង្គការអន្តរជាតិ ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីរៀបចំ និងផ្តល់

ការបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីពាក់ព័ន្ធខាងលើ។ ការអភិវឌ្ឍសមត្ថភាពនេះ ត្រូវផ្តោតលើផ្នែកសំខាន់ចំនួនពីរ រួមមាន៖

**១. ផ្នែកទំនាក់ទំនងសាធារណៈ:**

- របៀបរៀបចំសន្និសិទកាសែត
- របៀបសរសេរសេចក្តីប្រកាសព័ត៌មាន
- របៀបរៀបចំកញ្ចប់សម្ភារសម្រាប់អ្នកសារព័ត៌មាន
- របៀបឆ្លើយតបទៅនឹងប្រព័ន្ធផ្សព្វផ្សាយ/អ្នកសារព័ត៌មាន
- របៀបដោះស្រាយពេលមានវិបត្តិនៃការទំនាក់ទំនង

**២. ផ្នែកគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ**

**២.១ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្នែកបោះពុម្ពផ្សាយ**

- របៀបសរសេរព័ត៌មានទាន់ហេតុការណ៍
- របៀបសរសេរព័ត៌មានបែបបទយកការណ៍
- របៀបសរសេរចងក្រងអំពីជីវិតពិតនៃអ្នកទទួលផល
- របៀបសម្ភាសន៍ជាមួយអ្នកទទួលផល

**២.២ ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ**

**ក. ការផ្សព្វផ្សាយតាមទូរទស្សន៍**

- របៀបថតរូប
- របៀបកែរូបថត
- របៀបសរសេរអត្ថបទវីដេអូ
- របៀបថតវីដេអូ ដោយប្រើកាមេរ៉ាអាជីព និងទូរស័ព្ទឆ្លាតវៃ
- របៀបកែសម្រួលវីដេអូសម្រាប់ការផ្សាយតាមទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយប្រើកម្មវិធីកាត់តអាជីព និងទូរស័ព្ទឆ្លាតវៃ
- របៀបរៀបចំកិច្ចពិភាក្សាតុមូលតាមទូរទស្សន៍
- របៀបរៀបចំកម្មវិធីផ្សាយផ្ទាល់ (live) វីដេអូ ក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយប្រើប្រាស់ការភ្ជាប់ពីកាមេរ៉ាអាជីពទៅនឹងការផ្សព្វផ្សាយសង្គម (Facebook)

**ខ. ការផ្សព្វផ្សាយតាមវិទ្យុ**

- របៀបប្រើម៉ាស៊ីនថតសំឡេង ដើម្បីថតសំឡេងរបស់អ្នកទទួលផល
- របៀបសម្ភាសន៍ជាមួយអ្នកទទួលផល
- របៀបកែសម្រួល ឬកាត់តសំឡេងដែលបានថត ដោយប្រើកម្មវិធីអាជីព និងទូរសព្ទឆ្លាតវៃ

- របៀបរៀបចំកម្មវិធីជជែកពិភាក្សាតាមវិទ្យុ
- របៀបសរសេរអត្ថបទស្ពតវិទ្យុ
- របៀបសរសេរអត្ថបទវិទ្យុអំពីជីវិតពិត ឬបទយកការណ៍ទាក់ទងនឹងប្រធានបទណាមួយ
- របៀបរៀបចំកម្មវិធីវិទ្យុ ថតទុកជាមុន

**គ. ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម** (Facebook)

- របៀបរៀបចំផែនការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម
- របៀបរចនាការឱហ្សាញសម្រាប់បង្ហោះតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម
- របៀបភ្ជាប់ប្រធានបទផ្សាយពីទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមទៅគេហទំព័រ និងពីគេហទំព័រទៅប្រព័ន្ធផ្សព្វផ្សាយសង្គមវិញ
- របៀបបង្ហោះរូបថត អត្ថបទ វីដេអូ និងរូបភាពអមដោយព័ត៌មានខ្លីៗលើទំព័របណ្ដាញសង្គម
- របៀបវិភាគអំពីនិន្នាការនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម
- របៀបទាញយកទិន្នន័យ ឬបាយការណ៍លទ្ធផលនៃការផ្សព្វផ្សាយតាមរយៈបណ្ដាញសង្គម

## VII. ការតាមដាន និងវាយតម្លៃការអនុវត្តការងារទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន

ក្រុមការងារផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន អាចពិនិត្យកែសម្រួល និងស្វែងយល់អំពីតម្រូវការព័ត៌មានរបស់ក្រុមគោលដៅ តាមរយៈការតាមដាននិងវាយតម្លៃការអនុវត្តការងារទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន ដែលក្រុមការងារបានអនុវត្ត។ ការតាមដាន និងវាយតម្លៃអាចធ្វើទៅបានតាមរយៈវិធីសាស្ត្រគុណវិស័យនិងវិធីសាស្ត្របរិមាណវិស័យ។

### ក. វិធីសាស្ត្រគុណវិស័យ

វិធីសាស្ត្រគុណវិស័យ អាចធ្វើឡើងតាមរយៈការស្ទង់មតិក្រុមគោលដៅរៀងរាល់មួយឆ្នាំម្ដង ឬតាមពេលវេលាសមស្របណាមួយ ។ ការស្ទង់មតិនេះ អាចធ្វើឡើងក្នុងចំណោមភាគីពាក់ព័ន្ធ ដើម្បីតាមដានពីកម្រិត នៃការយល់ដឹងពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.** ភាពពេញចិត្តរបស់អ្នកទទួលផល ចំណុចខ្លាំង ចំណុចដែលត្រូវកែលម្អ និងដំណោះស្រាយនានា។ ការរៀបចំការស្ទង់មតិនេះ អាចធ្វើទៅបាននៅពេលមានការដាក់ចេញនូវកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមថ្មីៗ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន ។ ក្នុងករណីចាំបាច់ ការស្ទង់មតិគួរត្រូវអនុវត្តដោយធនធានខាងក្រៅ **ម.ជ.ជ.** ដើម្បីធានាភាពត្រឹមត្រូវនៃព័ត៌មាន និងងាយស្រួលក្នុងការផ្ដល់នូវអនុសាសន៍ ក្នុងការកែសម្រួលផែនការ យុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន។

ការរៀបចំនេះត្រូវឆ្លើយតបនឹងសំណួរសំខាន់ៗ ដូចខាងក្រោមៈ

- តើសកម្មភាពទំនាក់ទំនង និងផ្សព្វផ្សាយ ត្រូវបានរៀបចំគ្រប់ជ្រុងជ្រោយដែរឬទេ?

- តើអ្នកទទួលផលយល់ដឹង ឬកើនចំណេះដឹងពីកម្មវិធី ឬរបបនានា តាមរយៈការងារទំនាក់ទំនង និងផ្សព្វផ្សាយឬទេ?
- តើអ្នកទទួលផលបានធ្វើតាមការណែនាំអំពីកម្មវិធី/របបដែលបានផ្សព្វផ្សាយឬទេ?
- តើការវាយតម្លៃលើការទំនាក់ទំនង និងផ្សព្វផ្សាយកម្មវិធីជំនួយសង្គម និងរបបសំខាន់ៗជាមួយដៃគូពាក់ព័ន្ធមានទិដ្ឋភាពដូចម្តេច?
- តើមន្ត្រីពាក់ព័ន្ធបានចូលរួមរៀបចំផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយដែរឬទេ?
- តើត្រូវធ្វើដូចម្តេច ដើម្បីឱ្យការងារទំនាក់ទំនងនិងផ្សព្វផ្សាយកាន់តែមានប្រសិទ្ធភាព?
- តើការអនុវត្តសកម្មភាពទំនាក់ទំនង និងផ្សព្វផ្សាយត្រឹមត្រូវ តាមផែនការសកម្មភាពនិងថវិកាដែលបានគ្រោងដែរឬទេ?

**ខ. វិធីសាស្ត្របរិមាណវិស័យ**

វិធីសាស្ត្របរិមាណវិស័យ សំដៅដល់ការវាស់វែងចំនួនសម្ភារព័ត៌មាន អប់រំ និង ទំនាក់ទំនង ដែលត្រូវបានផលិត ធៀបទៅនឹងផែនការដែលបានគ្រោង។ ការទាញយកឯកសារគតិយុត្តផ្សេងៗពាក់ព័ន្ធនឹងកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.** ដូចជា ឯកសារគោលនយោបាយ សេចក្តីសម្រេច ឯកសារណែនាំ របាយការណ៍ សេចក្តីសង្ខេបគោលនយោបាយ សៀវភៅណែនាំ មាតិកាទំនាក់ទំនង និងការផ្សព្វផ្សាយផ្សេងៗទៀត តាមរយៈគេហទំព័រ ឬប្រព័ន្ធផ្សព្វផ្សាយឯកសារដទៃទៀតដូចជា យូធូប តេឡេក្រាម ហ្វេសប៊ុក។ល។

## VIII. ផែនការសកម្មភាព និងថវិកា

ផ្អែកលើការវិភាគស្ថានការណ៍ និងការកំណត់ជ្រើសរើសអន្តរាគមន៍ ឬវិធីសាស្ត្រក្នុងការទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានខាងលើ **ម.ជ.ជ.** បានដាក់ចេញនូវផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តការងារទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន រយៈពេល៣ឆ្នាំដំបូង (២០២៤-២០២៦) ដោយប្រើប្រាស់ថវិការបស់**ម.ជ.ជ.** ដែលត្រូវស្នើឡើងរៀងរាល់ឆ្នាំ និងថវិកាកៀរគរពីដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធនានា។ ផែនការសកម្មភាពនិងថវិកា មានភ្ជាប់នៅក្នុង **ឧបសម្ព័ន្ធ១** នៃឯកសារផែនការយុទ្ធសាស្ត្រទំនាក់ទំនងនិងផ្សព្វផ្សាយព័ត៌មាននេះ។

## IX. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននេះ គឺជាឯកសារបង្ហាញផ្លូវមួយដ៏សំខាន់សម្រាប់ក្រុមការងារផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន របស់ **ម.ជ.ជ.** ដឹកនាំអនុវត្តដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធនានារបស់ **ម.ជ.ជ.** សហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិនានា។ ការអនុវត្តផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន ដោយផ្អែកលើអន្តរាគមន៍ ឬវិធីសាស្ត្រខាងលើក្នុងពេលតំណាលៗគ្នា គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការបង្កើនការយល់ដឹងដល់គ្រប់ក្រុមគោលដៅ និងអ្នកពាក់ព័ន្ធនានាអំពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.** និងបង្កើនទំនុកចិត្ត

ភាពពេញចិត្ត និងការចូលរួមកាន់តែច្រើនក្នុងកម្មវិធីនិងរបបនានា។ ក្នុងនោះ ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីទទួលបន្ទុកផ្នែកទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន ក៏មានសារសំខាន់ផងដែរ ព្រោះវាជាមូលដ្ឋានក្នុងការរៀបចំផែនការ ការចងក្រង ការផលិត ការអនុវត្ត ការតាមដាន និងការវាយតម្លៃការអនុវត្តការងារទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយព័ត៌មាន។ ផែនការយុទ្ធសាស្ត្រនេះគប្បីត្រូវកែសម្រួល ឬមានភាពបត់បែនក្នុងការអនុវត្តផ្អែកលើលទ្ធផលនៃការតាមដាន និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្ត តាមរយៈវិធីសាស្ត្រគុណ វិស័យនិងវិធីសាស្ត្របរិមាណវិស័យ និងការដាក់ឱ្យអនុវត្តនូវកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមថ្មីៗ ដែលស្ថិតនៅក្រោមអាណត្តិកិច្ចរបស់ **ម.ជ.ជ.** សំដៅបង្កើនប្រសិទ្ធភាពនៃការ ផលិតនិងការបញ្ជូនព័ត៌មានទៅក្រុមគោលដៅឱ្យបានច្បាស់លាស់និងរហ័ស។

## ឧបសម្ព័ន្ធ ១៖ ផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តការងារទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន (២០២៤-២០២៦)

| អន្តរាគមន៍ | សកម្មភាព | ចំនួនសកម្មភាព | តម្លៃផលិត / អនុវត្ត (USD) | តម្លៃផ្សព្វផ្សាយ (USD) | ថេរវេលា | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ឆ្នាំទី 1 (2024) | | | | ឆ្នាំទី 2 (2025) | | | | ឆ្នាំទី 3 (2026) | | | |
| | | | | | ត្រីមាស 1 | ត្រីមាស 2 | ត្រីមាស 3 | ត្រីមាស 4 | ត្រីមាស 1 | ត្រីមាស 2 | ត្រីមាស 3 | ត្រីមាស 4 | ត្រីមាស 1 | ត្រីមាស 2 | ត្រីមាស 3 | ត្រីមាស 4 |
| **I. ការអនុវត្តអន្តរាគមន៍ ១-៩** | | | | | | | | | | | | | | | | |
| **១៖ ការធ្វើឱ្យប្រសើរឡើងនូវកិច្ចសហការ និងការសម្របសម្រួលអន្តរក្រសួង** | ១. រៀបចំកិច្ចប្រជុំដើម្បីបង្កើតក្រុមការងារអន្តរក្រសួង ស្ថាប័នដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលដែលធ្វើការងារផ្នែកកម្មវិធីជំនួយសង្គមនិងរបបសន្តិសុខសង្គម | 3 | 300 | | | | x | | x | | | | x | | | |
| | ២. រៀបចំកិច្ចប្រជុំ ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់ | 3 | 500 | | | | x | | x | | | | x | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | អនុវត្តរួមគ្នារបស់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលទាក់ទងនឹងកម្មវិធីជំនួយសង្គមនិងរបបសន្តិសុខសង្គម | | | | | | | | | | | | | | | |
| | ៣. រៀបចំបង្កើតឱ្យមានមណ្ឌលព័ត៌មាន ដើម្បីប្រមូលចងក្រង និងរក្សាទុករាល់ឯកសារគតិយុត្ត និងឯកសារនានាពាក់ព័ន្ធនឹងកម្មវិធីជំនួយសង្គម ដោយមានការចូលរួមពីក្រុមការងារអន្តរក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល | 1 | 5,000 | | | | x | | x | x | x | x | x | x | x | x |
| | ៤. រៀបចំព្រឹត្តិការណ៍ សិក្ខាសាលាផ្សព្វផ្សាយ និង/ឬវគ្គបណ្តុះបណ្តាលទាក់ទងនឹងផ្នែកទំនាក់ទំនងនិងផ្សព្វផ្សាយព័ត៌មានក្នុងចំណោមក្រុមការងារអន្តរក្រសួង ស្ថាប័នដៃគូអភិវឌ្ឍន៍ | 3 | 15,000 | | | | x | | | | x | | | | x | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | និងអង្គការសង្គមស៊ីវិល | | | | | | | | | | | | | | | |
| | ៥. រៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំរបស់ក្រុមការងារអន្តរក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល | 3 | 9,000 | | | | | x | | | | x | | | | x |
| | ៦. រៀបចំដំណើរទស្សនកិច្ចសិក្សា ឬការផ្លាស់ប្តូរចំណេះដឹងទៅវិញទៅមករវាងក្រុមការងារអន្តរក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល | 3 | 15,000 | | | | x | | | | x | | | | x | |
| | ៧. ការរៀបចំគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ស្លាកសញ្ញាសម្គាល់មូលនិធិជាតិជំនួយសង្គម និងការបោះពុម្ព | 1 | 5,000 | | | | x | x | | | | | | | | |
| **២៖ ការធ្វើឱ្យប្រសើរឡើងនូវភាពជាដៃគូក្នុងការ** | ១. រៀបចំកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ និង/ឬ សប្បុរសជននានា ដើម្បីពិភាក្សាអំពីការគាំទ្រដល់ការ | 3 | 900 | | x | | | | x | | | | x | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ទំនាក់ទំនង និង ផ្សព្វផ្សាយ** | អនុវត្តកម្មវិធីជំនួយសង្គមនិងរបបសន្តិសុខសង្គមនានា ដោយផ្តោតលើក្រុមគោលដៅជាក់លាក់។ ឧ. កញ្ចប់គ្រួសារ ( Unicef, GIZ, UNDP, ILO, Oxfam, ACCESS, F.I, CARE, Caritas (Cambodia), WV, etc.) | | | | | | | | | | | | | | | |
| | ២. រៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីស្វែងរក ឱកាសគាំទ្រដល់ការអនុវត្តសកម្មភាពផលិត និងផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងអំពីកម្មវិធីជំនួយសង្គមដល់ក្រុមគោលដៅបន្ថែមលើសកម្មភាពដែលអនុវត្តដោយផ្ទាល់ដោយក្រុមការងារទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននៃ | 3 | 300 | | x | | | | x | | | | x | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | មូលនិធិជាតិជំនួយសង្គម | | | | | | | | | | | | | | | |
| | ៣. រៀបចំកិច្ចប្រជុំពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ និងក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីកៀរគរធនធានក្នុងការបណ្តុះបណ្តាលសមត្ថភាព និងចំណេះដឹងរបស់មន្ត្រីទទួលបន្ទុកការងារទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន | 3 | 300 | | x | x | | | x | | | | x | | | |
| **៣៖ ការកសាងសមត្ថភាព** | ១. រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងកម្រិតខ្ពស់ម្តងយ៉ាងតិចក្នុងមួយឆ្នាំជាមួយក្រសួង ស្ថាប័នដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលពាក់ព័ន្ធ ដើម្បីចែករំលែកវឌ្ឍនភាព បញ្ហាប្រឈម និងផែនការបន្តនៃការអនុវត្តកម្មវិធីជំនួយសង្គមនិងរបបសន្តិសុខសង្គម | 3 | 25,000 | | | | | x | | | | x | | | | x |
| | ២. រៀបចំកិច្ចប្រជុំផ្សព្វផ្សាយផែនការកម្មវិធីជាតិជំនួយសង្គម | 3 | 15,000 | | | | | x | | | | x | | | | x |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ម្តងក្នុងមួយឆ្នាំដល់ភាគីពាក់ព័ន្ធ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្សព្វផ្សាយវឌ្ឍនភាព បញ្ហាប្រឈម និងផែនការបន្ត នៃការអនុវត្តកម្មវិធី ជំនួយសង្គមនិងរបបសន្តិសុខសង្គម | | | | | | | | | | | | | | | |
| | ៣. រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ឬបណ្តុះបណ្តាលនានាអំពីផែនការ ទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននៃមូលនិធិជាតិជំនួយសង្គមជូនដល់ភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបង្កើនការយល់ដឹង និងការចូលរួមក្នុងផែនការសកម្មភាព | 2 | 12,000 | | | | x | | | x | | | | | | |
| | ៤. រៀបចំព្រឹត្តិការណ៍សប្បុរសធម៌មួយយ៉ាងតិចក្នុងមួយឆ្នាំ ដើម្បីផ្សព្វផ្សាយអំពីកម្មវិធី | 2 | 20,000 | | | | | | | | | x | | | | x |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ជំនួយសង្គមជូនដល់អ្នកពាក់ព័ន្ធនានា និងកៀរគរធនធានសម្រាប់គាំទ្រសកម្មភាពជំនួយសង្គមណាមួយ | | | | | | | | | | | | | | | |
| | ៥. រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការទំនាក់ទំនងផ្លាស់ប្តូរឥរិយាបទសង្គម (SBCC) លើប្រធានបទសំខាន់ៗទាក់ទងនឹងកម្មវិធីជំនួយសង្គមដល់អ្នកពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តការងារកម្មវិធីជំនួយសង្គមជាក់លាក់ណាមួយ (កញ្ចប់គ្រួសារ TVET...) | 3 | 30,000 | | | | | x | | | x | | | x | | |
| | ៦. រៀបចំសិក្ខាសាលាផ្សព្វផ្សាយអនឡាញជាស៊េរីដើម្បីផ្សព្វផ្សាយអំពីកម្មវិធីជំនួយសង្គមនិងរបបសន្តិសុខ | 10 | 1,000 | | | | x | x | x | x | x | x | x | x | x | x |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សង្គមដល់អ្នកពាក់ព័ន្ធនានា (Serial Online Webinar) | | | | | | | | | | | | | | | |
| ៤៖ ការផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ និងការចូលរួម | ១. រៀបចំកិច្ចប្រជុំជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធនៃមូលនិធិជាតិជំនួយសង្គម និងក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីពិភាក្សាអំពីការបង្កើតមធ្យោបាយនានាដោយតម្រូវឱ្យមានការចូលរួមពីអ្នកទទួលផល និងអ្នកពាក់ព័ន្ធនានា ដើម្បីប្រមូល និងទទួលយកនូវបណ្តឹងតវ៉ា មតិត្រឡប់ និងសំណូមពរ នានាសំដៅកែលម្អការអនុវត្តការងារកម្មវិធីជំនួយសង្គម និងការរៀបចំសារអប់រំឱ្យស្របតាមតម្រូវការរបស់អ្នកទទួលផល | 1 | 100 | | | x | | | | | | | | | | |
| | ២. រៀបចំកិច្ចប្រជុំជាមួយ | 24 | 10,000 | | | x | x | x | x | x | x | x | x | x | x | x |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ក្រសួងព័ត៌មាន ដើម្បីស្នើសុំការគាំទ្រដល់ការ ផលិត និងផ្សព្វផ្សាយកម្មវិធីកិច្ចពិភាក្សាតាមវិទ្យុ | | | | | | | | | | | | | | | |
| | ៣. សហការជាមួយក្រុមប្រឹក្សាជាតិគាំពារសង្គម និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីរៀបចំវេទិកាសាធារណៈនៅថ្នាក់រាជធានី ខេត្ត ជុំវិញការអនុវត្តកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមនានា | 25 | 75,000 | | | | | x | | | | x | | | | x |
| | ៤. រៀបចំបង្កើតកម្មវិធីផ្សព្វផ្សាយផ្ទាល់តាមបណ្តាញផ្សព្វផ្សាយព័ត៌មានសង្គមដូចជាហ្វេសប៊ុក តេឡេក្រាម... ទាក់ទងនឹងកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម | 24 | 2,500 | | x | x | x | x | x | x | x | x | x | x | x | x |
| **៥៖ ទំនាក់ទំនង** | ១. ចងក្រង និងផលិតឧបករណ៍ | 20 | 15,000 | | x | x | x | | | x | | x | | x | x | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ជាមួយសារព័ត៌មាន** | ព័ត៌មាន អប់រំ និងទំនាក់ទំនង ដូចជា សារជាសំឡេង រូបភាព វីដេអូ ក្រាហ្វិក អត្ថបទអំពីកម្មវិធីជំនួយសង្គម ដើម្បីចែកផ្សាយទៅដល់អ្នកសារព័ត៌មាន និងស្នើសុំការផ្សព្វផ្សាយបន្ត | | | | | | | | | | | | | | | |
| | ២. រៀបចំកិច្ចប្រជុំជាមួយអ្នកសារព័ត៌មានយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ដើម្បីចែករំលែកព័ត៌មានអំពីកម្មវិធីជំនួយសង្គម វឌ្ឍនភាព បញ្ហាប្រឈម និងលទ្ធផលនៃការស្រាវជ្រាវនានា សំដៅឱ្យអ្នកសារព័ត៌មានជួយផ្សព្វផ្សាយព័ត៌មានបន្តដល់សាធារណៈជន | 6 | 12,000 | | | | x | | | x | | | | | | x |
| | ៣. រៀបចំដំណើរទស្សនកិច្ចសិក្សារបស់អ្នកសារព័ត៌មានទៅកាន់ទីតាំងរបស់អ្នកទទួលផល | 4 | 15,000 | | | | | x | | x | | x | | x | | x |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដើម្បីអ្នកសារព័ត៌មានបាន សិក្សារៀនសូត្រ និងប្រមូល ព័ត៌មានផ្សព្វផ្សាយអំពីលទ្ធផល នៃការអនុវត្តកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម | | | | | | | | | | | | | | | |
| ៦៖ ការអភិវឌ្ឍសម្ភារផ្សព្វផ្សាយព័ត៌មាន អប់រំ និងទំនាក់ទំនង (IEC) | ១. តាមដាន និងធ្វើបច្ចុប្បន្នភាពជាប្រចាំនូវគេហទំព័រសម្រាប់ផ្សព្វផ្សាយព័ត៌មាន និងរក្សាទុកនូវរាល់ឯកសារគតិយុត្តនានា | 1 | 15,000 | | x | x | x | x | x | x | x | x | x | x | x | x |
| | ២. តាមដាននិងធ្វើបច្ចុប្បន្នភាពជាប្រចាំនូវទំព័របណ្តាញផ្សព្វផ្សាយព័ត៌មានសង្គម (ហ្វេសប៊ុក) , Instagram | 1 | 500 | 3,000 | x | x | x | x | x | x | x | x | x | x | x | x |
| | ៣. តាមដាន និងធ្វើបច្ចុប្បន្នភាពជាប្រចាំនូវទំព័របណ្តាញផ្សព្វផ្សាយព័ត៌មានសង្គម | 1 | 300 | 500 | | | x | x | x | x | x | x | x | x | x | x |
| | ៤. តាមដាននិងធ្វើបច្ចុប្បន្នភាពជាប្រចាំនូវទំព័របណ្តាញ | 1 | 300 | 500 | | x | x | x | x | x | x | x | x | x | x | x |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ផ្សព្វផ្សាយព័ត៌មានសង្គម Instagram | | | | | | | | | | | | | | | |
| | ៥. តាមដាន និងធ្វើបច្ចុប្បន្នភាពជាប្រចាំនូវទំព័របណ្ដាញផ្សព្វផ្សាយព័ត៌មានសង្គម Tik Tok | 1 | 300 | 15,000 | | | x | x | x | x | x | x | x | x | x | x |
| | ៦. តាមដាន និងធ្វើបច្ចុប្បន្នភាពជាប្រចាំនូវទំព័របណ្ដាញផ្សព្វផ្សាយព័ត៌មានសង្គម Telegram | 1 | 300 | | x | x | x | x | x | x | x | x | x | x | x | x |
| | ៧. បង្កើត Mobile Application ដើម្បីសាធារណជនអាចទាញយក និងប្រើប្រាស់សម្រាប់ទទួលព័ត៌មាននានាអំពីកម្មវិធីជំនួយសង្គម និងព័ត៌មានបច្ចុប្បន្នភាពនានា | 1 | 15,000 | | | | | | x | x | x | x | x | x | x | x |
| | ៨. តាមដាន និងធ្វើបច្ចុប្បន្នភាពជាប្រចាំនូវទំព័របណ្ដាញ | 1 | 300 | | | x | x | x | x | x | x | x | x | x | x | x |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ផ្សព្វផ្សាយព័ត៌មានសង្គម Youtube | | | | | | | | | | | | | | |
| | ៩. ផលិត និងផ្សព្វផ្សាយកម្មវិធីទូរទស្សន៍<br>• ស្ពតទូរទស្សន៍ | 9 | 27,000 | 30,000 | x | x | | | x | | | | x | | |
| | • វីដេអូឯកសារ/បទសម្ភាសន៍ | 3 | 9,000 | 10,000 | x | x | | | x | x | x | x | x | x | x | x |
| | • វីដេអូបណ្តុះបណ្តាល | 3 | 12,000 | 10,000 | x | x | | | x | x | x | x | x | x | x | x |
| | • វីដេអូប្រវត្តិក្រុមគោលដៅ | 9 | 23,000 | 10,000 | | | | | x | x | x | x | x | x | x | x |
| | ១០. ការផលិត និងផ្សព្វផ្សាយកម្មវិធីវិទ្យុ<br>• កិច្ចពិភាក្សាតុមូលតាមវិទ្យុ | 25 | 10,000 | 10,000 | | | x | x | x | x | x | x | x | x | x | x |
| | • ល្ខោនវិទ្យុ | 25 | 10,000 | 10,000 | | | x | x | x | x | x | x | x | x | x | x |
| | • ស្ប៉តវិទ្យុ | 30 | 10,000 | 10,000 | | | x | x | x | x | x | x | x | x | x | x |
| | • សំឡេងផ្ទាល់របស់អ្នកទទួលផល | 25 | 5,000 | 10,000 | | | x | x | x | x | x | x | x | x | x | x |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | • បទយកការណ៍ខ្លីៗអំពីអត្ថប្រយោជន៍នៃការអនុវត្តកម្មវិធីជំនួយសង្គម | 6 | 6,000 | 10,000 | | | x | x | x | x | x | x | x | x | x | x |
| | • សេចក្ដីប្រកាសតាមវិទ្យុ | 8 | 1,500 | 5,000 | | | x | x | x | | | x | | | x | |
| | ១១. ការបោះពុម្ពផ្សាយ (Print)<br>• បដា (PVC Banner) - បោះពុម្ព និងបិទផ្សាយនូវបដាព័ត៌មាននៅតាមរដ្ឋបាលឃុំ មណ្ឌលសុខភាព ឬរោងប្រជុំតាមភូមិ | 3,000 | 3,000 | 45,000 | x | x | | | x | | | | | | | |
| | • ផលិត និងបោះពុម្ពផ្ទាំងរូបភាព (Poster) | 6,000 | 2,500 | 6,000 | x | x | | | x | x | | | | | | |
| | • ផលិត និងបោះពុម្ពស្ទីកគ័រព័ត៌មានអំពីកម្មវិធីជំនួយសង្គម (Sticker on social assistant) | 5,000 | 1,500 | 2,000 | | | x | x | | | x | | | x | | |
| | • ខិត្តបណ្ណ (Leaflet) | 10,000 | 3,000 | 5,000 | x | x | | | | x | | x | | x | | x |
| | • ការឱហ្យាញរូបភាពអមដោយចំណងជើងអត្ថបទ | 30 | 3,000 | 500 | x | x | | | | x | | x | | x | | x |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខ្លីៗ (Photos with captions) | | | | | | | | | | | | | | | |
| | • សម្រង់សម្ដីរបស់ក្រុមគោលដៅ/ដៃគូ (Beneficiary/partner quotes/stories) | 60 | 6,000 | 1,000 | | x | x | | x | x | x | x | x | x | x | x |
| | ១២. ការរៀបចំកិច្ចប្រជុំបង្កើតនិមិត្តសញ្ញាជាអត្តសញ្ញាណសម្គាល់ស្ថាប័ន និងជាមធ្យោបាយក្នុងការផ្សព្វផ្សាយអំពីស្ថាប័នដល់សាធារណៈជន<br>• ការបង្កើតនិមិត្តសញ្ញាសម្រាប់បំពាក់ (ឡូហ្គោ) ជាប់អាវ<br>• គំរូស្លាយបទបង្ហាញ<br>• ការដាក់និមិត្តសញ្ញាលើរូបថត និងវីដេអូ<br>• ព្រមទាំងបង្កើតនូវរបៀបប្រើប្រាស់និមិត្តសញ្ញា | 1 | 8,000 | 3,000 | | | x | | | | | | | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | (Branding) ឱ្យបានសមស្រប ដើម្បីធានាភាពត្រឹមត្រូវ និងច្បាស់លាស់ | | | | | | | | | | | | | | | |
| | ១៣. ការរៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សាជាតិគាំពារសង្គម និងក្រសួងប្រៃណីយ៍ និងទូរគមនាគមន៍អំពីការបង្កើតលេខទូរស័ព្ទ ៤ខ្ទង់សម្រាប់ប្រើប្រាស់ក្នុងក្របខណ្ឌកម្មវិធីជំនួយសង្គម | 1 | 500 | | | | x | | | | | | | | | |
| **៧៖ ទំនាក់ទំនង និងផ្សព្វផ្សាយសម្រាប់យន្តការកម្មវិធីជំនួយសង្គមឆ្លើយតបទៅនឹងគ្រោះអាសន្ន** | ១. រៀបចំកិច្ចប្រជុំជាមួយ ក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីស្វែងយល់ និងពិភាក្សាអំពីការប្រព្រឹត្តទៅនៃយន្តការផ្សព្វផ្សាយជាតិគាំពារសង្គម (NSPBM) | 1 | 500 | | | x | x | | | | | | | | | |
| | ២. អនុវត្តការប្រើប្រាស់យន្តការផ្សព្វផ្សាយជាតិគាំពារសង្គមយ៉ាងតិចចំនួន១ (តាមវិទ្យុ) | 24 | 15,000 | 20,000 | | | x | x | x | x | x | x | x | x | x | x |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដើម្បីផ្សព្វផ្សាយអំពីកម្មវិធីជំនួយសង្គមនិងរបបសន្តិសុខសង្គមណាមួយ | | | | | | | | | | | | | | | |
| | ៣. អនុវត្តការប្រើប្រាស់យន្តការផ្សព្វផ្សាយជាតិគាំពារសង្គមយ៉ាងតិចចំនួន១ (តាមទូរទស្សន៍) ដើម្បីផ្សព្វផ្សាយអំពីកម្មវិធីជំនួយសង្គមណាមួយ | 9 | 27,000 | 15,000 | | | x | x | x | x | x | x | x | x | x | x |
| | ៤. អនុវត្តការប្រើប្រាស់យន្តការផ្សព្វផ្សាយជាតិគាំពារសង្គមយ៉ាងតិចចំនួន១ (ផ្សាយតាមគេហទំព័ររបស់បណ្តាស្ថាប័នសារព័ត៌មាននានា) ដើម្បីផ្សព្វផ្សាយអំពីកម្មវិធីជំនួយសង្គមណាមួយ | 32 | 6,000 | 5,000 | | | x | x | x | x | x | x | x | x | x | x |
| | ៥. សហការជាមួយមន្ត្រីទទួលបន្ទុកការងារកម្មវិធីជំនួយសង្គមនៅថ្នាក់ក្រោមជាតិ ដើម្បីសហការ | 64 | 15,000 | 30,000 | | | x | x | x | x | x | x | x | x | x | x |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ផ្សព្វផ្សាយបន្តនូវកម្មវិធីជំនួយសង្គមណាមួយតាមរយៈការប្រើប្រាស់ឧគ្ឃោសនាសព្ទ វីម៉ក ម៉ូតូកង់បី កាណូត កិច្ចប្រជុំផ្ទាល់តាមភូមិ ឃុំ សហគមន៍ និងមធ្យោបាយនានា | | | | | | | | | | | | | | | |
| | ៦. បង្កើតក្រុមតេឡេក្រាម ដាច់ដោយឡែកជាមួយក្រសួង ស្ថាប័នដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន និងក្រុមតំណាងនានាដោយ ផ្តោតជាសំខាន់លើតែការផ្សព្វផ្សាយព័ត៌មានអំពីគ្រោះអាសន្ននានា ដោយសហការជាមួយក្រុមប្រឹក្សាជាតិគាំពារសង្គម និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | 1 | 1,500 | 500 | | x | x | | | | | | | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៨៖ការបញ្ជ្រាបមាតិកាកម្មវិធីជំនួយសង្គមក្នុងកម្មវិធីសិក្សា | ១. រៀបចំកិច្ចប្រជុំជាមួយក្រុមប្រឹក្សាជាតិគាំពារសង្គម និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិភាក្សាអំពីលទ្ធភាពក្នុងការបញ្ចូលមេរៀនស្តីពីកម្មវិធីជំនួយសង្គមទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ | 1 | 5000 | | | | | x | x | x | x | | | | | |
| | ២. សហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន ឬអ្នកពាក់ព័ន្ធនានា រៀបចំ ផលិតសម្ភារព័ត៌មានចម្រុះដែលអាចឱ្យសិស្សានុសិស្សសិក្សារៀនសូត្រនៅតាមបណ្ណាល័យ ឬទាញយកមកសិក្សាតាមរយៈអនឡាញ | 1 | 25,000 | 30,000 | x | x | x | x | x | | | | | | | |
| | ៣. រៀបចំផែនការសកម្មភាពចុះអប់រំ និងផ្សព្វផ្សាយដោយផ្ទាល់ | 48 | 30,000 | 100,000 | | | | | x | x | x | x | x | x | x | x |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នៅតាមសាលារៀន គ្រឹះស្ថានសិក្សារដ្ឋ និងឯកជន ព្រមទាំងបិទផ្សាយសម្ភារបោះពុម្ពចែកផ្សាយតាមសាលារៀន ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលនានាផងដែរ | | | | | | | | | | | | | | | |
| **៩៖ ការតាមដាន និងវាយតម្លៃ** | ១. ការរៀបចំសិក្សាស្រាវជ្រាវដើមគ្រាអំពីការយល់ដឹងរបស់ក្រុមគោលដៅលើការអនុវត្តកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមនានា និងប្រសិទ្ធភាពនៃការអនុវត្តផែនការផ្សព្វផ្សាយ និងទំនាក់ទំនងនៃកម្មវិធីជាតិជំនួយសង្គម (វិធីសាស្ត្រគុណវិស័យ) | 1 | 30,000 | | | | x | x | | | | | | | | |
| | ២. ការរៀបចំសិក្សាស្រាវជ្រាវចុងគ្រាអំពីការយល់ដឹងរបស់ក្រុមគោលដៅលើការអនុវត្តកម្ម | 1 | 30,000 | | | | | | | | | | | | | x |



ម

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិធីជំនួយសង្គមនានា និងប្រសិទ្ធភាពនៃការអនុវត្តផែនការផ្សព្វផ្សាយ និងទំនាក់ទំនងនៃកម្មវិធីជាតិជំនួយសង្គម (វិធីសាស្ត្រគុណវិស័យ) | | | | | | | | | | | | | | | |
| | ៣. ការរៀបចំបង្កើតសូចនាករនៃការអនុវត្តផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានទៅតាមប្រភេទនៃឧបករណ៍ព័ត៌មាន អប់រំ និងទំនាក់ទំនង វិធីសាស្ត្រផ្សព្វផ្សាយ និងលទ្ធផលរំពឹងទុកនៃការផ្សព្វផ្សាយនីមួយៗ (វិធីសាស្ត្របរិមាណវិស័យ) | 1 | 500 | | x | | | | | | | | | | | |
| | ៤. រៀបចំកិច្ចប្រជុំពិនិត្យតាមដានវឌ្ឍនភាព បញ្ហាប្រឈម និងផែនការបន្តរៀងរាល់បីខែម្តងទាក់ទងនឹងការអនុវត្ត | 10 | 1,000 | | x | x | x | x | x | x | x | x | x | x | x | x |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន | | | | | | | | | | | | | | | |
| | **សរុបផ្នែកទី១** | | **643,100** | **396,500** | | | | | | | | | | | | |
| **II.** | **ផែនការអនុវត្តការបណ្តុះបណ្តាលសមត្ថភាពរបស់មន្ត្រី ផ្នែកទំនាក់ទំនងនិងផ្សព្វផ្សាយព័ត៌មាន** | | | | | | | | | | | | | | | |
| 1. | **ផ្នែកទំនាក់ទំនងសាធារណៈ**<br>–របៀបរៀបចំសន្និសិទកាសែត<br>–របៀបសរសេរសេចក្តីប្រកាសព័ត៌មាន<br>–របៀបរៀបចំកញ្ចប់សម្ភារសម្រាប់អ្នកសារព័ត៌មាន<br>–របៀបឆ្លើយតបទៅនឹងប្រព័ន្ធផ្សព្វផ្សាយអ្នកសារព័ត៌មាន/<br>–របៀបដោះស្រាយពេលមានវិបត្តិនៃការទំនាក់ទំនង | 3 | 5,000 | | | x | x | x | | | | | | | | |
| 2. | **ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្នែកបោះពុម្ពផ្សាយ**<br>–របៀបសរសេរព័ត៌មានទាន់ហេតុការណ៍<br>–របៀបសរសេរព័ត៌មានបែប | 3 | 3,000 | | | x | x | x | | | | | | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បទយកការណ៍<br>–របៀបសរសេរចងក្រងអំពីជីវិតពិតនៃអ្នកទទួលផល<br>–របៀបសម្ភាសន៍ជាមួយអ្នកទទួលផល | | | | | | | | | | | | | | | |
| 3. | **ជំនាញផ្នែកទូរទស្សន៍**<br>–របៀបថតរូប<br>–របៀបកែរូបថត<br>–របៀបសរសេរអត្ថបទវីដេអូ<br>–របៀបថតវីដេអូ ដោយប្រើកាមេរ៉ាអាជីព និងទូរស័ព្ទឆ្លាតវៃ<br>–របៀបកែសម្រួលវីដេអូសម្រាប់ការផ្សាយតាមទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយសង្គមដោយប្រើកម្មវិធីកាត់តអាជីព និងទូរស័ព្ទឆ្លាតវៃ<br>–របៀបរៀបចំកិច្ចពិភាក្សាតុមូលតាមទូរទស្សន៍<br>–របៀបរៀបចំកម្មវិធីផ្សាយ | 3 | 6,000 | | x | x | x | x | x | | | | | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ផ្ទាល់<br>Live (វីដេអូ ក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម) ដោយប្រើប្រាស់ការភ្ជាប់ពីកាមេរ៉ាអាជីពទៅនឹងផ្សព្វផ្សាយសង្គម (Facebook) | | | | | | | | | | | | | | | |
| 4. | **ជំនាញផ្នែកវិទ្យុ**<br>–របៀបប្រើម៉ាស៊ីនថតសំឡេងដើម្បីថតសំឡេងរបស់អ្នកទទួលផល<br>–របៀបសម្ភាសន៍ជាមួយអ្នកទទួលផល<br>–របៀបកែសម្រួលកាត់ត/សំឡេងដែលបានថតដោយប្រើកម្មវិធីអាជីព និងទូរស័ព្ទឆ្លាតវៃ<br>–របៀបរៀបចំកម្មវិធីជជែកពិភាក្សាតាមវិទ្យុ<br>–របៀបសរសេរអត្ថបទស្ពតវិទ្យុ<br>–របៀបសរសេរអត្ថបទវិទ្យុអំពី | 3 | 6,000 | | | | x | x | x | | | | | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ជីវិតពិត ឬបទយកការណ៍ទាក់ទងនឹងប្រធានបទណាមួយជាក់លាក់<br>–របៀបរៀបចំកម្មវិធីវិទ្យុ ថតទុកជាមុន | | | | | | | | | | | | | | | |
| 5. | **ជំនាញផ្នែកប្រព័ន្ធផ្សព្វផ្សាយសង្គម** (Facebook)<br>–របៀបរៀបចំផែនការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម<br>–របៀបរចនាការឌីហ្សាញសម្រាប់បង្ហោះតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម<br>–របៀបភ្ជាប់ប្រធានបទផ្សាយពីទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមទៅគេហទំព័រ និងពីគេហទំព័រទៅប្រព័ន្ធផ្សព្វផ្សាយសង្គមវិញ<br>–របៀបបង្ហោះរូបថត អត្ថបទ វីដេអូនិងរូបភាពអមដោយព័ត៌មានខ្លីៗលើទំព័របណ្ដាញ | 3 | 6,000 | | x | x | x | | x | | | | | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សង្គម<br>– របៀបវិភាគអំពីនិន្នាការនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម<br>– របៀបទាញយកទិន្នន័យ ឬរបាយការណ៍លទ្ធផលនៃការផ្សព្វផ្សាយតាមរយៈបណ្ដាញសង្គម | | | | | | | | | | | | | | | |
| **សរុបផ្នែកទី២** | | | **26,000** | **0** | | | | | | | | | | | | |
| **សរុបផ្នែកទី១ និងទី២** | | | **725,400** | **396,500** | | | | | | | | | | | | |

មូលនិធិជាតិជំនួយសង្គម

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ

លេខទំនាក់ទំនង: (+៨៥៥) ៩២ ២១៩ ៨៨៨ | ១៥ ២១៩ ៨៨៨

បណ្តាញសង្គមរបស់យើង:

គាំទ្រដោយ៖

Australian Aid

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

giz